# ប្រាសាទបានក្អួង

ប្រាសាទបានក្អួងស្ថិតនៅភូមិបានក្អួង ស្រុកប្រាសាទ ខេត្តសុរិន្ទ ចម្ងាយពីព្រំដែនខ្មែរ ច្រកអូស្មាច់ ប្រហែល៣៥គម (រូបលេខ១)។

ប្រាសាទនេះសាងនៅរវាងស.វទី១១-១២ និងធ្លាប់ជួសជុលតាមបែបអាណាស្ទីឡូហ្សីស (Anastylosis method) នៅឆ្នាំ១៩៧២ដោយលោក Vance R. Childress។ វិធីជួសជុលតាមបែបអាណាស្ទីឡូហ្សីស គឺប្រើថ្ម ឬវត្ថុដើមដែលមាននៅប្រាសាទ ដើម្បីជួសជុលប្រាសាទឡើងវិញ។ នៅលើផ្តែរនៃទិសខាងកើត និងខាងត្បូងផ្នែកកណ្តាលមានបង្ហាញចម្លាក់ព្រះឥន្ទជិះដំរី (រូបលេខ២-៣) (ភាគច្រើនចម្លាក់ព្រះឥន្ទជិះដំរីនៅតាមប្រាសាទនានាបែរទៅទិសខាងកើត ប៉ុន្តែប្រាសាទនេះមានបែរទៅទិសខាងត្បូងមួយទៀត របៀបនេះអាចមានខ្លះដែរនៅតំបន់អង្គរ)។

តាមអ្នកភូមិ (ខ្មែរសុរិន្ទ) រស់នៅម្តុំប្រាសាទនេះបានប្រាប់ថា រហូតមកដល់សព្វថ្ងៃនៅមានទំនៀមរៀបពិធីទាក់ទងនឹងរឿងស្តេចដំរីស និងនាងសក់ក្រអូប (ឬនាងទន់សត្រា)នាខែចេត្ររៀងរាល់ឆ្នាំ។ រឿងទាក់ទងនឹងនាងសក់ក្រអូប និងស្តេចដំរីសមានប្រជាប្រិយណាស់នៅម្តុំប្រាសាទនេះ ក៏ដូចជាខេត្តសុរិន្ទទាំងមូល។ រឿងព្រេងនេះមិនល្បីតែនៅស្រុកខ្មែរទេ សូម្បីតែនៅស្រុកលាវនៅម្តុំភូមិក្បែរប្រាសាទណាងអ៊ីង (នៅជាប់ព្រំដែនលាវ និងខ្មែរ មានភូមិជនជាតិខ្មែរនៅទីនោះ) (រូបលេខ៤) ក៏មាននិយាយទាក់ទងនឹងរឿងនាងសក់ក្រអូប (ឬស្តេចដំរីស) ដែរ។

អ្នកនៅខេត្តសុរិន្ទជឿលើស្តេចដំរីសនោះណាស់ ដូច្នោះហើយជារៀងរាល់ឆ្នាំគេតែងតែរៀបពិធីធំទាក់ទងនឹងស្តេចដំរីសនៅក្នុងខេត្ត (រូបលេខ៥)។ បើនិយាយអំពីរឿងស្តេចដំរីសនេះ គឺវែងឆ្ងាយណាស់ ទាំងនៅក្នុងជំនឿ ទំនៀមទម្លាប់ នយោបាយ និងសង្គម។ ទំនៀម ឬជំនឿលើដំរី (ដំរីស) ជ្រាបចូលនៅក្នុងសង្គមខ្មែរ បុរាណខ្លាំងណាស់។ ឧទាហរណ៍ រឿងដំរីជាមួយព្រះពុទ្ធក៏មានជាចម្លាក់នៅតាមប្រាសាទខ្មែរ ហើយដែល

ច្បាស់មែនទែននៅប្រាសាទព្រះបាលិលេយ្យនៅអង្គរធំ (សាងនៅស.វទី១២ ក្នុងរាជ្យនៃព្រះបិតារបស់ព្រះបាទជ័យវរ្ម័នទី៧) ។

ក្នុងប្រវត្តិសាស្ត្រខ្មែរក៏មាននិយាយច្រើនអំពីទម្លាប់ ឬក៏ចំណូលចិត្តនៃការទាក់ដំរីរបស់ព្រះរាជាដែលមានចារជាសិលាចារឹក (ឧ. ព្រះបាទជ័យវរ្ម័នទី៣) សរសេរនៅក្នុងព្រះរាជពង្សាវតារ និងកំណត់ត្រារបស់អ៊ីរ៉ុប (ព្រះបាទអង្គច័ន្ទនៅស.វទី១៦)។ល។ គំនិតទាក់ទងនឹងស្តេចដំរីស ពោលគឺជានិមិត្តរូបនៃអំណាចរបស់ស្តេច។



រូបលេខ១. ប្រាសាទបានក្លួង



រូបលេខ២៖ ផ្តែ ព្រះឥន្ទជិះដំរី



រូបលេខ៣៖ ផ្តែ ព្រះឥន្ទជិះដំរី

អត្ថបទដោយ៖ លោក ញឹម សុជារិទ្ធ




រូបលេខ២៨៖ ប្រាសាទណាងអ៊ីង



រូបលេខ២៩៖ បុណ្យដំរីនៅសុរិន្ទ

អរិយធម៌ខ្មែរ
AMS
KHMER CIVILIZATION

អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ